ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក

CAMPU LONPAC INSURANCE 柬 埔 寨 大 众 伦 平 保 险

# យើងខ្ញុំធានារ៉ាប់រងលោកអ្នក
# ក្នុងប្រទេសកម្ពុជា

## កិច្ចសន្យាធានារ៉ាប់រងលើអំពើចោរកម្ម

ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងសេវាកម្មរបស់ក្រុមហ៊ុនយើងខ្ញុំ សូមមេត្តាសរសេរលិខិតមកក្រុមទទួលពាក្យបណ្តឹងរបស់យើងខ្ញុំ ៖

| | | |
|---|---|---|
| អាសយដ្ឋានទំនាក់ទំនង | : | **ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី**<br>ជាន់ទី៧ នៃអគារកម្ពុប៊ែង<br>ផ្ទះលេខ ២៣ ផ្លូវ ១១៤<br>សង្កាត់ផ្សារថ្មី ២<br>ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា<br>ប្រអប់សំបុត្រ ១៥៥៦ |
| លេខទូរស័ព្ទ | : | + ៨៥៥ ២៣ ៩៦៦ ៩៦៦ / ៩៩៨ ២០០ / ៩៨៦ ២៧៩ |
| លេខទូរសារ | : | + ៨៥៥ ២៣ ៩៨៦ ៣០៨ / ២៧៣ |
| អ៊ីមែល | : | complaint@campulonpac.com.kh |
| គេហទំព័រ | : | www.campulonpac.com.kh |

**ក្នុងករណីមានឧប្បត្តិហេតុកើតឡើង**

**លេខទូរសព្ទ័ប្រចាំការ២៤ម៉ោង**

+ ៨៥៥ ១៦ ៨១០ ៩៩៩ / ៨២០ ៩៩៩

+ ៨៥៥ ១៧ ៧៩៩ ៩០២ / ៧៩៩ ៩០៣

អ៊ីមែល : claims@campulonpac.com.kh

សំគាល់:

ក្នុងករណីមានវិវាទកើតឡើង ឬការខុសឆ្គងអត្ថន័យណាមួយនៅក្នុងកិច្ចសន្យាធានារ៉ាប់រងជាភាសាខ្មែរ នោះក្រុមហ៊ុនធានារ៉ាប់រងយើងខ្ញុំនឹងយកកិច្ចសន្យាធានារ៉ាប់រងជាភាសាអង់គ្លេសជាសំអាង ។

យើងខ្ញុំសូមស្នើជាពិសេសថា សូមលោកអ្នកអានកិច្ចសន្យាធានារ៉ាប់រងនេះអោយបានហ្មត់ចត់ និងផ្ញើត្រឡប់មកកាន់ក្រុមហ៊ុនយើងខ្ញុំវិញភ្លាម ប្រសិនបើមានភាពចាំបាច់ត្រូវកែតម្រូវ ។

## កិច្ចសន្យាធានារ៉ាប់រងលើអំពើចោរកម្ម

**ដោយហេតុថា** បុគ្គលដែលត្រូវបានធានារ៉ាប់រង ដែលមានឈ្មោះនៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចសន្យាធានារ៉ាប់រងនេះបានធ្វើសំណើ និងសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី (តទៅនេះហៅកាត់ថា "ក្រុមហ៊ុន") ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងបានយល់ព្រមនឹងត្រូវបានចាត់ទុកថាមានលក្ខណៈជាកិច្ចសន្យា និងមានសុពលភាព និងជាមូលដ្ឋាននៃកិច្ចសន្យានេះ បានបង់ ឬយល់ព្រមបង់បុព្វលាភធានារ៉ាប់រង ដូចបានចែងក្នុងតារាងឧបសម្ព័ន្ធ បានបញ្ជាក់ជូនខាងលើ ដើម្បីទទួលបានសំណងដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ។

**ដោយហេតុនេះ កិច្ចសន្យានេះផ្តល់នូវសក្ខីកម្មដែលបញ្ជាក់ថា** ដោយផ្អែកលើ ខ ចែង ករណីលើកលែង ដែនកំណត់ និងលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ឬមានចែងនៅក្នុងបដ្ឋិលេខបន្ថែម ឬបើមិនដូច្នោះត្រូវបានបញ្ជាក់ក្នុងកិច្ចសន្យាធានារ៉ាប់រងនេះថា នៅក្នុងអំឡុងពេលនៃការធានារ៉ាប់រងណាមួយ ដូចដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចសន្យាធានារ៉ាប់រងនេះ ឬនៅក្នុងអំឡុងពេលបន្ថែមណាមួយ ដែលក្រុមហ៊ុនអាចទទួលយកការបង់បុព្វលាភធានារ៉ាប់រងសម្រាប់ការបន្តកិច្ចសន្យាធានារ៉ាប់រងនេះ :

**ក.** ប្រសិនបើទ្រព្យសម្បត្តិដែលមានការធានារ៉ាប់រង ឬផ្នែកណាមួយនៃទ្រព្យសម្បត្តិនោះ ដូចមានបញ្ជាក់ជូននៅក្នុងតារាងឧបសម្ព័ន្ធដែលមានភ្ជាប់មកជាមួយឯកសារនេះ ខណៈដែលទ្រព្យសម្បត្តិទាំងនោះស្ថិតនៅក្នុងបរិវេណអគារដែលមានបញ្ជាក់ជូនក្នុងតារាងឧបសម្ព័ន្ធបានបាត់បង់ :

- (i) ដោយសារអំពើចោរកម្មបណ្តាលមកពីការចេញចូលបរិវេណអគារនេះដោយប្រើកម្លាំង និងហិង្សា ឬប្រព្រឹត្តដោយបុគ្គលណាម្នាក់ ឬបុគ្គលទាំងឡាយ (ក្រៅពីនិយោជិតរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង) ដែលលាក់បាំងដោយខុសច្បាប់ ឬ
- (ii) បង្កឡើងដោយអំពើប្លន់ប្រដាប់អាវុធ ឬកាន់កាប់ក្នុងគោលបំណងយកទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង
  - ១) តាមរយៈការប្រើអំពើហិង្សាទៅលើអ្នកថែរក្សា
  - ២) តាមរយៈការធ្វើអោយភ័យខ្លាចដោយអំពើហិង្សា
  - ៣) ពីអ្នកថែរក្សាដែលត្រូវបានសម្លាប់ ឬធ្វើអោយបាត់បង់ស្មារតី
- (iii) ក្នុងករណីសម្រាប់តែលំនៅដ្ឋានឯកជន និង/ឬអគារស្នាក់នៅ/ផ្ទះល្វែង ដែលទ្រព្យសម្បត្តិទាំងនោះត្រូវបានដណ្តើមយក ឬយកចេញពីបរិវេណអគារដោយមានបំណងមិនស្របច្បាប់ ឬ

**ខ.** ប្រសិនបើមានការខូចខាតលើទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ឬលើបរិវេណអគារ នោះការខូចខាតទាំងនោះនឹងក្លាយជាបន្ទុករបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដែលការខូចខាតទាំងនោះបណ្តាលមកពីអំពីចោរកម្មដូចដែលបានរៀបរាប់ខាងលើ ឬការប៉ុនប៉ងណាមួយ ។

ក្រុមហ៊ុននឹងធ្វើសំណង សម្រាប់ការខូចខាតដល់បុគ្គលដែលត្រូវបានធានារ៉ាប់រង:

១. ចំពោះការបាត់បង់ទាំងឡាយទៅតាមតម្លៃទីផ្សារ នៅពេលដែលការបាត់បង់នោះកើតឡើង (ដោយមិនគិតបញ្ចូលអត្ថប្រយោជន៍គ្រប់ប្រភេទ) និង/ឬ

២. តម្លៃជួសជុសការខូចខាត

ប៉ុន្តែមិនត្រូវលើសចំនួនទឹកប្រាក់សរុបដែលត្រូវបានធានារ៉ាប់រង ពាក់ព័ន្ធនឹងផ្នែកណាមួយដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ឬប្រាំភាគរយ (៥%) នៃចំនួនទឹកប្រាក់ធានារ៉ាប់រងសរុបសម្រាប់ការខូចខាតលើបរិវេណអគារ ឬចំនួនទឹកប្រាក់ធានារ៉ាប់រងសរុបនៅក្នុងអំឡុងពេលធានារ៉ាប់រងណាមួយឡើយ ។

## ករណីលើកលែង

កិច្ចសន្យាធានារ៉ាប់រងនេះមិនធ្វើសំណងលើ :

១. ការបាត់បង់ ឬការខូចខាតបណ្តាលមកពីអំពើចោរកម្ម ដូចមានចែងខាងលើ ឬការប៉ុនប៉ងណាមួយដែលបង្កឡើងដោយគ្រួសាររបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង និយោជិត អ្នកបម្រើតាមផ្ទះ ឬបុគ្គលណាម្នាក់ដែលរស់នៅស្របច្បាប់ក្នុងបរិវេណអគារ លើកលែងតែមានចែងនៅក្នុងផ្នែក ក (ii)ខាងលើ ។

២. ការបាត់បង់ ឬការខូចខាតដែលបង្កឡើងដោយផ្ទាល់ ឬប្រយោលដោយសារសង្គ្រាម ការឈ្លានពាន ទង្វើរបស់សត្រូវបរទេស អរិភាព (ទោះបីជាមាន ឬមិនមានការប្រកាសសង្គ្រាមក៏ដោយ) សង្គ្រាមស៊ីវិល អំពើឧទ្ទាម បដិវត្តន៍ អំពើបះបោរ កូដកម្ម កុប្បកម្ម ការរំជើបរំជួលសង្គម ការប្រើអំណាចយោធា ឬការដណ្តើមអំណាច ការក្រោកឈរប្រឆាំងរបស់ប្រជាជន ឬការរឹបអូស ឬការបំផ្លាញតាមបញ្ជារបស់រដ្ឋាភិបាល ឬអាជ្ញាធរសាធារណៈ ឬដោយសារតែលទ្ធផលផ្ទាល់ ឬប្រយោលនៃការកើតឡើងពីសកម្មភាពណាមួយខាងលើ និងក្នុងករណីនៃការទាមទារណាមួយយោងតាមកិច្ចសន្យាធានារ៉ាប់រងនេះ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវបញ្ជាក់អះអាងថា ការបាត់បង់ ឬការខូចខាតនោះបានកើតឡើងដោយឯកឯង ហើយគ្មានទាក់ទងនឹង ឬកើតឡើងដោយ ឬត្រូវបានរួមចំណែកបង្កឡើងដោយ ឬអាចត្រូវបានរកឃើញថាកើតឡើងដោយសារតែការកើតឡើងនៃសកម្មភាពទាំងនោះណាមួយ ឬជា

លទ្ធផលនៃសកម្មភាពទាំងនោះ ហើយប្រសិនបើខ្វះ ឬគ្មានការបញ្ជាក់អះអាងបែបនោះទេ ក្រុមហ៊ុននឹងមិនទទួលខុសត្រូវក្នុងការទូទាត់សំណងដែលពាក់ព័ន្ធនឹងការទាមទារនោះឡើយ ។

៣. ការបាត់បង់ ឬការខូចខាតមេដាយ កាក់ប្រាក់ វត្ថុកម្រ រូបចម្លាក់ ស្នាដៃសិល្បៈ សៀវភៅសរសេរដោយដៃ សៀវភៅកម្រ ប្លង់ ទម្រង់ គំរូ ពុម្ព ការរចនា ប័ណ្ណសម្គាល់កម្មសិទ្ធិ សញ្ញាប័ណ្ណ រូបិយាណត្តិ ប័ណ្ណសន្យាសងប្រាក់ ប្រាក់មូលធនបត្រ ត្រា ឯកសារសម្គាល់កម្មសិទ្ធិ ឬសៀវភៅពាណិជ្ជកម្ម លើកលែងតែមានបញ្ជាក់ជាពិសេសនៅក្នុងតារាងឧបសម្ព័ន្ធ ។

៤. ការបាត់បង់ ឬការខូចខាតដែលកើតមានឡើងខណៈពេលដែលបរិវេណអគារ គ្មានការប្រើប្រាស់ក្នុងរយៈពេលលើសពីដប់បួន (១៤) ថ្ងៃជាប់ៗគ្នា ឬការប្រើប្រាស់អគារផ្សេងពីអ្វីដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ លើកលែងតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនជាមុន និងបុព្វលាភធានារ៉ាប់រងបន្ថែមដែលតម្រូវដោយក្រុមហ៊ុន ត្រូវបានបង់ ។

៥. (ក) ការគ្រោះថ្នាក់ ការបាត់បង់ ការបំផ្លិចបំផ្លាញ ឬការខូចខាតទ្រព្យសម្បត្តិណាមួយ ឬការបាត់បង់ ឬការចំណាយ ទោះបណ្តាលមកពី ឬកើតចេញពីអ្វីក៏ដោយ ឬការខាតបង់ផ្នែកហិរញ្ញវត្ថុដែលកើតឡើងដោយផ្ទាល់ ឬប្រយោល ឬរួមចំណែកបង្កឡើងដោយ ឬកើតចេញពីការភាយចំហាយជាតិវិទ្យុសកម្មអ៊ីយ៉ុង ឬការបំពុលដោយសារធាតុវិទ្យុសកម្ម ដែលភាយចេញពីឥន្ធនៈនុយក្លេអ៊ែរ ឬកាកសំណល់នុយក្លេអ៊ែរពីចំហេះឥន្ធនៈ នុយក្លេអ៊ែរ សម្រាប់តែគោលបំណងនៃករណីលើកលែងនេះប៉ុណ្ណោះ ចំហេះត្រូវរាប់បញ្ចូលនូវដំណើរការនៃកាបំបែកអាតូមនុយក្លេអ៊ែរដោយឯកឯង។

(ខ) គ្រោះថ្នាក់ ការបាត់បង់ ការបំផ្លិចបំផ្លាញ ឬការខូចខាតដែលបង្កឡើងដោយផ្ទាល់ ឬប្រយោល ឬរួមចំណែកបង្កឡើងដោយ ឬកើតចេញពីសព្វាវុធនុយក្លេអ៊ែរ ។

**បរិវេណអគារ** ដែលមានរៀបរាប់នៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយឯកសារនេះ សំដៅលើតែអគារប៉ុណ្ណោះ និងមិនរាប់បញ្ចូលទីធ្លា សួនច្បារ អគាររអម ឬអាគារបន្ទាប់បន្សំផ្សេងទៀត លើកលែងតែមានការបញ្ជាក់លម្អិតនៅក្នុងតារាងឧបសម្ព័ន្ធ។

## លក្ខខណ្ឌនានា

១. ការធានារ៉ាប់រងនេះ មិនអាចចាប់ផ្តើមបានឡើយ រហូតដល់បុព្វលាភធានារ៉ាប់រងត្រូវបានបង់ និងទទួលដោយក្រុមហ៊ុន ហើយលិខិតទទួលយកជាផ្លូវការ និងកិច្ចសន្យាធានារ៉ាប់រងរបស់ក្រុមហ៊ុនត្រូវបានចេញជូន ហើយគ្មានការបង់ប្រាក់ទាក់ទងនឹងបុព្វលាភធានារ៉ាប់រង ត្រូវបានចាត់ទុកជាការបង់ប្រាក់ទៅឱ្យក្រុមហ៊ុនឡើយ លុះត្រាតែទម្រង់បោះពុម្ពនៃបង្កាន់ដៃដែលត្រូវបានចុះហត្ថលេខាដោយអ្នកតំណាងផ្លូវការ ឬដែលត្រូវបានអនុញ្ញាតយ៉ាងត្រឹមត្រូវរបស់ក្រុមហ៊ុន ត្រូវបានចេញជូន ។

២. បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវចាត់វិធានការសមស្រប ដើម្បីការពារការខូចខាត ឬការបាត់បង់នូវទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ។

៣. រាល់ការជូនដំណឹងទាំងអស់ត្រូវបានតម្រូវឱ្យផ្តល់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងជូនក្រុមហ៊ុន ចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងផ្ញើទៅកាន់សាខា ឬភ្នាក់ងារក្រុមហ៊ុនដែលជាទីកន្លែងដែលកិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានចេញជូន ហើយការជូនដំណឹង ឬការយល់ដឹងពីអ្វីមួយពាក់ព័ន្ធនឹងកិច្ចសន្យាធានារ៉ាប់រងនេះ ឬការទាមទារណាមួយស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ មិនត្រូវបានចាត់ទុកថាជាការជូនដំណឹងទៅកាន់ ឬជាការយល់ដឹងរបស់ក្រុមហ៊ុនឡើយ លុះត្រាតែត្រូវបានផ្តល់ជូន ហើយគ្មានការកែប្រែលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងនេះ និងគ្មានការឯកភាពចំពោះបដិលេខណាមួយនឹងមានសុពលភាពឡើយ លុះត្រាតែការកែប្រែលក្ខខណ្ឌ ឬបដិលេខដូចគ្នានេះ ត្រូវបានចុះហត្ថលេខា ឬទទួលស្គាល់ដោយតំណាងពេញសិទ្ធិរបស់ក្រុមហ៊ុន ។

៤. ក្នុងករណីកើតឡើងនូវហេតុការណ៍ណាមួយ ឬទំនងជាអាចកើតឡើងនូវបណ្តឹងទាមទារសំណងណាមួយ យោងតាមកិច្ចសន្យាធានារ៉ាប់រងនេះ:

(ក) បុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវជូនដំណឹងជាបន្ទាន់ដល់មន្ត្រីនគរបាល និងក្រុមហ៊ុន ហើយត្រូវផ្តល់នូវជំនួយសមហេតុផលទាំងអស់ ដើម្បីបង្កឱ្យមានការរកឃើញ និងធានាការផ្តន្ទាទោសជនល្មើស និងដើម្បីតាមដាន និងយកមកវិញនូវទ្រព្យសម្បត្តិដែលបានបាត់នោះ ។

(ខ) បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងដល់ក្រុមហ៊ុនក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីបានដឹងអំពីហេតុការណ៍ដែលបណ្តាលអោយមានបណ្តឹងទាមទារសំណង នូវរបាយការណ៍លម្អិតជាលាយលក្ខណ៍អក្សរអំពី ការខូចខាត ឬការបាត់បង់ដោយមានបញ្ជាក់អំពីការវាយតម្លៃទ្រព្យសម្បត្តិនីមួយៗដែលបានបាត់បង់ និងទំហំនៃការខូចខាតដែលបានកើតឡើងដោយមិនរាប់បញ្ចូលនូវអត្ថប្រយោជន៍គ្រប់ប្រភេទ ។

(គ) បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវផ្តល់ជូនក្រុមហ៊ុននូវព័ត៌មាន និងភស្តុតាងលម្អិត ឯកសារ ឬអ្វីផ្សេងទៀតទាំងអស់ និងត្រូវអនុវត្ត និងធ្វើការធានា ព្រមទាំងធ្វើអ្វីៗទាំងអស់ដូចដែលក្រុមហ៊ុនអាចនឹងតម្រូវដោយសមហេតុផល អោយធ្វើការបញ្ជាក់លើការទាមទារសំណង និងស្វែងរក និងដាក់ទោសជនល្មើស និងតាមដាន និងស្វែងរកទ្រព្យសម្បត្តិដែលបានបាត់ និងផ្តល់សំណងដល់ក្រុមហ៊ុនវិញនូវទឹកប្រាក់ដែលក្រុមហ៊ុនត្រូវបង់ ឬត្រូវទទួលខុសត្រូវចំពោះសំណង ស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ ។

ក្រុមហ៊ុនទទួលបន្ទុកលើការចំណាយទាំងអស់ពាក់ព័ន្ធនឹងព័ត៌មានលម្អិត ភស្តុតាង ការធានា និងអ្វីៗទាំងអស់ ដូចដែលក្រុមហ៊ុនអាចទាមទារដោយផ្អែកលើកម្មវត្ថុខាងលើ ឬកម្មវត្ថុណាមួយ ឬតម្រូវការឯកសារផ្សេងៗទៀតដើម្បីជាភស្តុតាងបន្ថែមគាំទ្រដល់ការទាមទារសំណង ។

ទោះជាក្នុងករណីណាក៏ដោយ ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតណាមួយដែលមិនត្រូវបានជូនដំណឹងមកក្រុមហ៊ុនក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពេលកើតមានហេតុការណ៍ទាំងនោះ ។

៥. ក្រុមហ៊ុនអាចប្រើមធ្យោបាយផ្លូវច្បាប់ទាំងអស់ នៅពេលណាមួយក៏បាន ដោយធ្វើការចំណាយផ្ទាល់ខ្លួនក្នុងនាមជាបុគ្គលដែលត្រូវបានធានារ៉ាប់រង សម្រាប់ការទទួលបានមកវិញនូវទ្រព្យសម្បត្តិណាមួយដែលបាត់បង់ ហើយបុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវផ្តល់ជំនួយសមហេតុផលទាំងអស់សម្រាប់គោលបំណងនោះ ។ ក្រុមហ៊ុនមានសិទ្ធិលើទ្រព្យសម្បត្តិណាមួយដែលបានបាត់បង់ ក្រោយពេលដែលសំណងត្រូវបានបង់ជូនសម្រាប់ការបាត់បង់នោះ ហើយបុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវបំពេញភារកិច្ច និងធ្វើការធានាទាំងអស់លើទ្រព្យសម្បត្តិទាំងនោះ ដូចដែលអាចតម្រូវដោយសមហេតុផលអោយធ្វើដូច្នេះ ប៉ុន្តែបុគ្គលដែលត្រូវបានធានារ៉ាប់រងគ្មានសិទ្ធិប្រគល់ ឬលះបង់នូវទ្រព្យសម្បត្តិណាមួយជូនក្រុមហ៊ុនឡើយ ។

៦. នៅក្នុងករណីមានបណ្តឹងទាមទារសំណងចំពោះការលួច ឬអំពើចោរកម្ម បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវផ្តល់ភស្តុតាង ដើម្បីបញ្ជាក់ដល់ក្រុមហ៊ុនថាទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងការទាមទារសំណង ពិតជាបានបាត់បង់ដោយសារការលួច និងអំពើចោរកម្ម និងមិនមែនគ្រាន់តែជាការច្រឡំដៃ ឬភ្លេចបាត់នោះទេ ។

៧. ភ្លាមៗបន្ទាប់ពីមានការបាត់បង់ ឬការខូចខាតណាមួយកើតឡើង ចំនួនទឹកប្រាក់ធានារ៉ាប់រងសរុបត្រូវបានកាត់បន្ថយដោយចំនួនទឹកប្រាក់នៃការបាត់បង់ ឬការខូចខាតនោះ ហើយចំនួនទឹកប្រាក់ធានារ៉ាប់រងសរុបដែលបានកាត់បន្ថយនោះ គឺជាដែនកំណត់នៃការទទួលខុសត្រូវរបស់ក្រុមហ៊ុន ក្នុងករណីកើតមានការបាត់បង់ ឬការខូចខាតបន្ថែមផ្សេងទៀត ដែលអាចកើតមានឡើងក្នុងអំឡុងពេលធានារ៉ាប់រងបច្ចុប្បន្ន លើកលែងតែក្រុមហ៊ុនយល់ព្រមលើការបង់បុព្វលាភធានារ៉ាប់រងបន្ថែម ដើម្បីបំពេញអោយគ្រប់នូវចំនួនទឹកប្រាក់ធានារ៉ាប់រងសរុបឡើងវិញ ។

៨. ក្រុមហ៊ុនអាចធ្វើអោយដូចដើមវិញ ជួសជុល ឬជំនួសទ្រព្យសម្បត្តិដែលបានបាត់បង់ ឬខូចខាត ឬបរិវេណអគារដែលបានខូចខាតតាមករណីជាក់ស្តែងជំនួសអោយការបង់ថ្លៃបាត់បង់ ឬខូចខាត និងអាចចូលរួមជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងផ្សេងទៀតដើម្បីធ្វើដូច្នេះ ក្នុងករណីទ្រព្យសម្បត្តិនោះត្រូវបានធានារ៉ាប់រងដោយក្រុមហ៊ុនផ្សេងទៀត ។ បន្ទាប់ពីបានបង់ថ្លៃទាមទារសំណង សម្រាប់ការបាត់បង់ស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះរួច ទ្រព្យសម្បត្តិដែលបានបាត់បង់នោះត្រូវក្លាយជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ។

៩. ប្រសិនបើនៅពេលមានការបាត់បង់ ឬការខូចខាតលើទ្រព្យសម្បត្តិដែលធានាដោយកិច្ចសន្យាធានារ៉ាប់រងនេះ មានការធានារ៉ាប់រងប្រភេទណាមួយផ្សេងទៀត ដែលត្រូវបានអនុវត្តដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង ដែលធានាលើទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងណាមួយ ឬផ្នែកណាមួយនៃទ្រព្យសម្បត្តិនោះ នោះការទទួលខុសត្រូវរបស់ក្រុមហ៊ុន ត្រូវបានកម្រិតមកត្រឹមអត្រាសមាមាត្រដែលអាចកំណត់បានចំពោះការបាត់បង់ ឬការខូចខាតនោះតែប៉ុណ្ណោះ ។ ទ្រព្យសម្បត្តិនីមួយៗ ដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវអនុវត្តដាច់ដោយឡែកពីគ្នាដោយផ្អែកលើលក្ខខណ្ឌនេះ ។

១០. គ្មានចំណុចណាមួយនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ផ្តល់សិទ្ធិណាមួយប្រឆាំងនឹងក្រុមហ៊ុន ទៅអោយបុគ្គលណាមួយក្រៅពីបុគ្គលដែលត្រូវបានធានា-រ៉ាប់រងឡើយ ហើយក្រុមហ៊ុននឹងមិនត្រូវបានភ្ជាប់កាតព្វកិច្ច ដោយសារការផ្ទេរអត្ថប្រយោជន៍របស់បុគ្គលដែលត្រូវបានធានារ៉ាប់រងឡើយ លើកលែងតែដោយសារករណីទទួលមរណភាព និងលុះត្រាតែ ឬរហូតទាល់តែក្រុមហ៊ុនធ្វើការប្រកាសតាមរយៈបដិ្ឋលេខថា ការធានារ៉ាប់រងនោះនឹងត្រូវបានបន្ត ។

១១. ប្រសិនបើសំណើ ឬការប្រកាសរបស់បុគ្គលដែលត្រូវធានារ៉ាប់រងមិនពិតក្នុងទិដ្ឋភាពណាមួយ ឬប្រសិនបើការពិតជាក់ស្តែងណាមួយដែលប៉ះពាល់ដល់ហានិភ័យនោះ ត្រូវបានបង្ហាញដោយមិនត្រឹមត្រូវនៅក្នុងសំណើ ឬការប្រកាសនោះ ឬសំណើសុំបន្តការធានារ៉ាប់រងថ្មីណាមួយធ្វើឡើងតាមរយៈការផ្តល់ព័ត៌មានមិនពិត ឬការបង្ហាញព័ត៌មានមិនពិត ឬការផ្តល់ព័ត៌មានដោយបង្ខំ ឬប្រសិនបើការទាមទារសំណងណាមួយធ្វើឡើងតាមរយៈការក្លែងបន្លំ ឬត្រូវបានបំផ្លើស ឬប្រសិនបើការប្រកាស ឬការអះអាងមិនពិតណាមួយត្រូវបានធ្វើឡើងគាំទ្រដល់ការទាមទារសំណងទាំងនោះ នោះកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវចាត់ទុកជាអសារបង់ ។

១២. ការធានារ៉ាប់រងនេះអាចត្រូវបានបញ្ឈប់នៅពេលណាមួយ តាមសំណើរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ ថ្ងៃ ក្នុងករណីនេះក្រុមហ៊ុននឹងបង្វិលសងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងវិញចំនួនកៅសិបភាគរយ(៩០%) នៃបុព្វលាភធានារ៉ាប់រងដែលនៅសល់សម្រាប់រយៈពេលដែលនៅមានសុពលភាព គិតចាប់ពីថ្ងៃសុំបញ្ឈប់នៃកិច្ចសន្យាធានារ៉ាប់រងនេះ ដោយក្នុងលក្ខខណ្ឌថាពុំមានបណ្តឹងទាមទារសំណងណាមួយកើតឡើងក្នុងអំឡុងពេលនៃការធានារ៉ាប់រងនេះទេ។ កិច្ចសន្យាធានារ៉ាប់រងនេះក៏អាចត្រូវបានបញ្ឈប់ផងដែរតាមជម្រើសរបស់ក្រុមហ៊ុនដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ថ្ងៃ ជាមុនទៅកាន់អាសយដ្ឋានដែលគេស្គាល់ចុងក្រោយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង

ក្នុងករណីនេះលោកអ្នកមានសិទ្ធិទទួលបានការបង្វិលសងបុព្វលាភមកវិញ តាមសមាមាត្រនៃបុព្វលាភសម្រាប់រយៈពេលដែលនៅមានសុពលភាពគិតចាប់ពីថ្ងៃសុំបញ្ឈប់ការធានារ៉ាប់រង ។

រាល់ការសុំបញ្ឈប់ការធានារ៉ាប់រង លោកអ្នកនឹងមិនត្រូវបានបង្វិលសងនូវបុព្វលាភធានារ៉ាប់រងឡើយ ប្រសិនបើបុព្វលាភនោះត្រូវបានបង់ក្នុងកម្រិតអប្បបរមា ។

១៣. ក្នុងករណីមានវិវាទកើតឡើងទាក់ទងនឹងចំនួនទឹកប្រាក់ដែលត្រូវធ្វើសំណង ស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ ( ការទទួលខុសត្រូវ ត្រូវបានទទួលស្គាល់) នោះវិវាទត្រូវបញ្ជូនទៅដោះស្រាយដោយមជ្ឈត្តករមួយរូប ដែលតែងតាំងឡើងជាលាយលក្ខណ៍អក្សរដោយភាគីវិវាទ ឬប្រសិនបើពួកគេមិនអាចព្រមព្រៀងគ្នាយកមជ្ឈត្តករតែមួយរូបដែលត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីនីមួយៗ នោះវិវាទនឹងត្រូវបានដោះស្រាយដោយមជ្ឈត្តករពីររូប ដែលត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីនីមួយៗ ក្នុងរយៈពេលពីរខែនៃប្រតិទិនបន្ទាប់ពីត្រូវបានតម្រូវ ជាលាយលក្ខណ៍អក្សរអោយធ្វើដូច្នេះដោយភាគីនីមួយៗ ឬក្នុងករណីក្រុមមជ្ឈត្តករមិនព្រមព្រៀងគ្នាយកមជ្ឈត្តករ វិនិច្ឆ័យមួយរូប ដែលត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរដោយក្រុមមជ្ឈត្តករ មុនពេលចាប់ផ្តើមធ្វើសេចក្តីសម្រេចចិត្ត។ មជ្ឈត្តករវិនិច្ឆ័យត្រូវអង្គុយជាមួយក្រុមមជ្ឈត្តករ និងធ្វើជាអធិបតីក្នុងកិច្ចប្រជុំរបស់ពួកគេ ហើយការចេញមជ្ឈត្តិវិនិច្ឆ័យគឺជាលក្ខខណ្ឌជាមុននៃសិទ្ធិប្តឹងណាមួយប្រឆាំងនឹងក្រុមហ៊ុន ។

១៤. ទោះក្នុងករណីណាក៏ដោយ ក្រុមហ៊ុនមិនត្រូវទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតក្រោយផុតរយៈពេលដប់ពីរ ( ១២) ខែ គិតចាប់ពីពេលមានការបាត់បង់ ឬការខូចខាតនោះកើតឡើង លើកលែងតែការទាមទារនោះជាកម្មវត្ថុនៃការប្តឹងដែលកំពុងរង់ចាំការវិនិច្ឆ័យ ឬការធ្វើមជ្ឈត្តការ ។

១៥. ការគោរព និងអនុវត្តតាមយ៉ាងត្រឹមត្រូវនូវ ខចែង បញ្ញត្តិ លក្ខខណ្ឌ និងបដិលេខនៃកិច្ចសន្យាធានារ៉ាប់រងនេះដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងកម្រិតដែលវាមានការពាក់ព័ន្ធនឹងចំណុចដែលខ្លួនត្រូវធ្វើ ឬគោរពតាម ហើយភាពពិតប្រាកដនៃសេចក្តីប្រកាសអះអាង និងចម្លើយនៅក្នុងសំណើដែលបានលើកឡើង គឺជាលក្ខខណ្ឌជាមុននៃការទទួលខុសត្រូវរបស់ក្រុមហ៊ុន ក្នុងការធ្វើសំណងយោងតាមកិច្ចសន្យាធានារ៉ាប់រងនេះ ។

១៦. **លក្ខខណ្ឌធានាចំពោះបុព្វលាភធានារ៉ាប់រង**

វាជាលក្ខខណ្ឌមូលដ្ឋាន និងពិសេសបំផុតនៃកិច្ចសន្យាធានារ៉ាប់រងនេះ ដែលបុព្វលាភធានារ៉ាប់រងត្រូវតែបង់ និងទទួលបានដោយក្រុមហ៊ុនក្នុងរយៈពេលសាមសិប ( ៣០) ថ្ងៃ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមកិច្ចសន្យាធានារ៉ាប់រងនេះ /បដិលេខ/ វិញ្ញាបនបត្របន្តការធានារ៉ាប់រងថ្មី ។

ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពទេ នោះកិច្ចសន្យានេះត្រូវបានបញ្ឈប់ដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនមានសិទ្ធិទទួលបានបុព្វលាភធានារ៉ាប់រងតាមសមាមាត្រសម្រាប់រយៈពេលដែលខ្លួនស្ថិតក្នុងហានិភ័យ ។

ប្រសិនបើបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ស្របតាមការធានានេះ ត្រូវបានទទួលដោយភ្នាក់ងារមានការអនុញ្ញាតរបស់ក្រុមហ៊ុន ប្រាក់នេះត្រូវចាត់ទុកថាបានទទួលដោយក្រុមហ៊ុនសម្រាប់គោលបំណងនៃការធានានេះ ហើយកាតព្វកិច្ចក្នុងការកំណត់ថា បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ ត្រូវបានទទួលដោយបុគ្គលម្នាក់រួមទាំងភ្នាក់ងារធានារ៉ាប់រងដែលមិនត្រូវបានអនុញ្ញាតអោយទទួលបុព្វលាភធានារ៉ាប់រងនោះ ត្រូវធ្លាក់ទៅលើក្រុមហ៊ុន ។

រាល់លក្ខខណ្ឌ និង ខ ចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ ។

១៧. ក្រុមហ៊ុនមិនទទួលខុសត្រូវឡើយចំពោះការបាត់បង់ ឬការខូចខាតណាមួយដែលបង្កឡើងដោយ ឬកើតឡើងដោយសារតែសកម្មភាពនៃការឆបោករបស់បុគ្គលណាមួយនៅក្នុងអត្ថន័យនៃនិយមន័យបទល្មើសឆបោកដូចខាងក្រោម ។

ជនណាដែលតាមរយៈការបោកបន្លំជនណាម្នាក់ទៀត បើទោះជាអំពើបន្លំនោះជាការបញ្ចុះបញ្ចូលតែម្យ៉ាង ឬជាអំពើចំបងមួយ ឬមិនមែនក៏ដោយ :

( ក) បញ្ចុះបញ្ចូលដោយបន្លំ ឬដោយមិនស្មោះត្រង់ជនណាម្នាក់ទៀត អោយចាញ់បោកព្រមប្រគល់ទ្រព្យសម្បត្តិណាមួយទៅអោយជនណាម្នាក់ ឬព្រមព្រៀងអោយជនម្នាក់នោះរក្សាទ្រព្យសម្បត្តិនោះទុក ឬ

( ខ) បញ្ចុះបញ្ចូលដោយចេតនាជនណាម្នាក់អោយចាញ់បោកព្រមធ្វើអំពើ ឬមិនធ្វើអំពើណាមួយ ដែលជននោះនឹងមិនធ្វើ ឬមិនខកខានធ្វើឡើយ ប្រសិនបើខ្លួនពុំត្រូវបានគេបោកបន្លំទេនោះ ហើយដែលអំពើ ឬការមិនធ្វើអំពើនោះបង្កអោយមាន ឬអាចបង្កអោយមានការខូចខាត ឬបង្កគ្រោះថ្នាក់ដល់បុគ្គលដទៃទៀត ទាំងផ្លូវកាយ ផ្លូវចិត្ត កេរ្តិ៍ឈ្មោះ ឬទ្រព្យសម្បត្តិ ។

អោយឈ្មោះថា "**អំពើឆបោក**" ។

១៨. ក្រុមហ៊ុនមិនទទួលខុសត្រូវឡើយចំពោះការបាត់បង់ ឬការខូចខាតណាមួយដែលបង្កឡើង ឬកើតឡើងដោយសារតែសកម្មភាពមិនស្របច្បាប់នៃការរំលោភលើសេចក្តីទុកចិត្ត ដោយបុគ្គលណាមួយនៅក្នុងអត្ថន័យនៃនិយមន័យបទល្មើសរំលោភលើសេចក្តីទុកចិត្តដែលជាបទឧក្រិដ្ឋដូចខាងក្រោម ។

"ជនណាក៏ដោយ ដែលត្រូវបានផ្តល់ឱ្យនូវទ្រព្យសម្បត្តិក្នុងលក្ខណៈណាមួយ ឬនូវអំណាចគ្រប់គ្រងលើទ្រព្យសម្បត្តិ យក ឬផ្លាស់ប្តូរទ្រព្យសម្បត្តិនោះ ដោយភាពមិនស្មោះត្រង់ឱ្យទៅជាការប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រើប្រាស់ ឬបោះបង់ដោយភាពមិនស្មោះត្រង់នូវទ្រព្យសម្បត្តិនោះ ដោយរំលោភលើវិធាន ច្បាប់ដែលបញ្ញត្តិពីរបៀបដោះបន្ទុកលើការផ្ញើទុកនោះ ឬរំលោភលើកិច្ចសន្យាតាមផ្លូវច្បាប់ដោយជាក់លាក់ ឬដោយតុណ្ហីភាពដែលអនុញ្ញាតអោយខ្លួនរួចបន្ទុកពីការផ្ញើទុកនោះ ឬដោយចេតនាបង្កអោយបុគ្គលដទៃទទួលរងនូវការខូចខាតដោយអំពើខាងលើ ត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើសរំលោភលើសេចក្តីទុកចិត្ត" ។

**បដ្ឋិលេខលើកលែងករណីភេរវកម្ម**
ទោះបីជាមានបទប្បញ្ញត្តិណាមួយផ្ទុយទៅនឹងការធានារ៉ាប់រងនេះ ឬបដ្ឋិលេខបន្ថែមណាមួយក៏ដោយ វាជាការព្រមព្រៀងគ្នាថា ការធានារ៉ាប់រងនេះមិនរួមបញ្ចូលការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយណាមួយដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោលដែលបណ្តាលមកពី ឬពាក់ព័ន្ធនឹងសកម្មភាពភេរវកម្មណាមួយដោយមិនគិតពីបុព្វហេតុ ឬព្រឹត្តិការណ៍ណាមួយផ្សេងទៀត ដែលរួមចំណែករួមគ្នា ឬជាលទ្ធផលបង្កឱ្យមានការបាត់បង់នោះ ។

សម្រាប់គោលបំណងនៃបដ្ឋិលេខនេះ សកម្មភាពភេរវកម្មសំដៅលើសកម្មភាពមួយដែលមានជាអាទិ៍ដូចជា ការប្រើកម្លាំង ឬអំពើហិង្សា និង/ឬ ការគំរាមកំហែងប្រើកម្លាំង ឬអំពើហិង្សារបស់បុគ្គលណាមួយ ឬក្រុមណាមួយ បើទោះបីជាប្រព្រឹត្តតែម្នាក់ឯង ឬក្នុងនាម ឬពាក់ព័ន្ធនឹងអង្គភាពណាមួយ ឬរដ្ឋាភិបាល សម្រាប់គោលបំណងនយោបាយ សាសនា មនោគមវិជ្ជា ឬគោលបំណងស្រដៀងគ្នានេះ ដែលរួមមានចេតនាប្រើឥទ្ធិពលលើរដ្ឋាភិបាលណាមួយ និង/ឬដើម្បីបង្កការភ័យខ្លាចដល់សាធារណជន ឬក្រុមណាមួយនៃសាធារណជននោះ ។

បដ្ឋិលេខនេះ ក៏មិនរួមបញ្ចូលផងដែរនូវការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយអ្វីក៏ដោយដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬប្រយោលដែលកើតឡើងមកពី ឬពាក់ព័ន្ធនឹងការចាត់វិធានការណាមួយដើម្បីគ្រប់គ្រង ទប់ស្កាត់ បង្ក្រាប ឬ ទាក់ទងនឹងសកម្មភាពភេរវកម្មតាមវិធីណាមួយ ។

ប្រសិនបើក្រុមហ៊ុនចោទប្រកាន់ថា តាមរយៈហេតុផលនៃការលើកលែងនេះ ការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយណាមួយ មិនត្រូវបានធានារ៉ាប់រងដោយកិច្ចសន្យាធានារ៉ាប់រងនេះ បន្ទុកនៃការបញ្ជាក់អ្វីដែលផ្ទុយត្រូវធ្លាក់លើបុគ្គលដែលត្រូវបានធានារ៉ាប់រង ។

ក្នុងករណីដែលផ្នែកណាមួយនៃបដ្ឋិលេខនេះ ត្រូវបានរកឃើញថាមិនមានសុពលភាព ឬមិនអាចអនុវត្តបាន ផ្នែកផ្សេងទៀតដែលនៅសល់ នៅតែស្ថិតនៅជាធរមាន និងមានសុពលភាពពេញលេញ ។

NMA2921
០៨/១០/២០០១

**ខ ចែងស្តីពីប្រព័ន្ធព័តិមានវិទ្យា**

ការខូចខាតទ្រព្យសម្បត្តិដែលគ្រប់ដណ្តប់ស្របតាមការធានារ៉ាប់រងនេះ សំដៅដល់ការខូចខាតផ្នែករូបវន្តនៃលក្ខណៈសំខាន់របស់ទ្រព្យសម្បត្តិ។ ការខូចខាតផ្នែករូបវន្តនៃលក្ខណៈសំខាន់របស់ទ្រព្យសម្បត្តិមិនរាប់បញ្ចូលការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រឡើយ ជាពិសេសការផ្លាស់ប្តូរមិនល្អនៅក្នុងទិន្នន័យ ឬកម្មវិធីកុំព្យូទ័រដែលបង្កឡើងដោយ ការលុប ការប្រែប្រួល ឬការខូចទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដើម ។

ដោយហេតុនេះ ចំណុចខាងក្រោមនេះ ត្រូវបានលើកលែងពីការធានារ៉ាប់រងនេះ :

(ក) ការបាត់បង់ ឬការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ ជាពិសេសការផ្លាស់ប្តូរមិនល្អនៅក្នុងទិន្នន័យ ឬកម្មវិធីកុំព្យូទ័រដែលបណ្តាលមកពីការលុបចោល ការប្រែប្រួល ឬការខូចទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដើម និងការបាត់បង់ដោយសារការផ្អាកអាជីវកម្មដែលបង្កឡើងដោយសារការបាត់បង់ ឬការខូចខាតនោះ ។ ទោះបីជាមានការលើកលែងនេះក៏ដោយ ការបាត់បង់ ឬការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ ដែលជាលទ្ធផលដោយផ្ទាល់នៃការខូចខាតផ្នែករូបវន្តដែលមានការធានារ៉ាប់រងដល់លក្ខណៈសំខាន់នៃទ្រព្យសម្បត្តិត្រូវបានធ្វើសំណង។

(ខ) ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីភាពអន់ថយផ្នែកមុខងារ ភាពអាចរកបាន កម្រិតនៃការប្រើប្រាស់ ឬភាពអាចបើកមើលបាននៃទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ និងការខាតបង់ដោយសារការផ្អាកអាជីវកម្ម ដែលបង្កឡើងដោយសារការបាត់បង់ ឬការខូចខាតនោះ ។

(Munich Re)

**ខ ចែងស្តីអំពីការដាក់កំហិតទណ្ឌកម្ម និងករណីលើកលែង** (LMA 3100)

គ្មានក្រុមហ៊ុនធានារ៉ាប់រងណាមួយ អាចផ្តល់ការធានារ៉ាប់រង និងទទួលខុសត្រូវចំពោះការផ្តល់ប្រាក់សំណងណាមួយ ឬផ្តល់អត្ថប្រយោជន៍ណាមួយដែលស្ថិតនៅក្នុងដែនកំណត់នៃបុរេលក្ខខណ្ឌនៃការធានារ៉ាប់រងនោះបានឡើយ ដែលការផ្តល់សំណង ឬអត្ថប្រយោជន៍ទាំងនោះធ្វើអោយក្រុមហ៊ុនធានារ៉ាប់រងប្រឈមមុខនឹងការដាក់ទណ្ឌកម្មណាមួយ ការហាមឃាត់ ឬការដាក់កម្រិតដែលស្ថិតនៅក្រោមសេចក្តីសម្រេចរបស់អង្គការ សហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ច្បាប់ ឬនិយតកម្មរបស់សហគមន៍អ៊ឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក។

## ការធានា/បដិលេខ/ខសន្យាដែលត្រូវអនុវត្ត ដូចដែលមានចែងក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យាធានារ៉ាប់រង

**ខ ចែង ស្តីពីតម្លៃទីផ្សារ**

នៅក្នុងករណីមានការបាត់បង់ទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ដែនកំណត់នៃប្រាក់សំណង គឺជាតម្លៃដែលបានធានារ៉ាប់រង ឬតាមតម្លៃទីផ្សារនៃទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ដោយយកតម្លៃណាមួយដែលទាបជាងគេ ដកនឹងចំនួនទឹកប្រាក់ដែលត្រូវចូលរួមចំណែកធ្វើសំណង និងចំនួនទឹកប្រាក់ផ្សេងទៀតដែលបុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវទទួលខុសត្រូវ ស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ ។

សម្រាប់គោលបំណងនៃលក្ខខណ្ឌនេះ ពាក្យថា តម្លៃទីផ្សារ សំដៅលើតម្លៃរបស់ទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង នៅពេលខូចខាត ឬបាត់បង់ ដកតម្លៃអត្រាចូលរួមសម្រាប់ការផ្លាស់ប្តូរថ្មី ការសឹករេចរឹល និង/ឬការកាត់រំលស់ ។

សម្រាប់គោលបំណងនៃលក្ខខណ្ឌនេះ ក្នុងករណីមានវិវាទអំពីតម្លៃទីផ្សារនៃទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង តម្លៃនោះត្រូវបានកំណត់ដោយការប៉ាន់ស្មានតម្លៃ ដែលក្រុមហ៊ុនទទួលបានពីរោងចក្រផលិត ភ្នាក់ងារលក់ផ្តាច់មុខ ឬភ្នាក់ងារដែលទទួលបានការអនុញ្ញាត ជើងសារដែលទទួលបានការអនុញ្ញាត ឬក្រុមហ៊ុនចែកចាយដែលទទួលបានការអនុញ្ញាត សម្រាប់តម្លៃចំណាយនៃការធ្វើអោយដូចដើម ឬការជួសជុលទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងដែលខូចខាត ឬបាត់បង់អោយមានសភាពដូចមុនពេលបាត់បង់ ឬខូចខាត ។

ក្នុងករណីមានការបាត់បង់ ឬការខូចខាត ហើយគ្មានរោងចក្រផលិត គ្មានភ្នាក់ងារផ្តាច់មុខ ឬគ្មានភ្នាក់ងារដែលទទួលបានការអនុញ្ញាត គ្មានជើងសារដែលទទួលបានការអនុញ្ញាត ឬគ្មានក្រុមហ៊ុនចែកចាយដែលទទួលបានការអនុញ្ញាតសម្រាប់ទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង នោះការប៉ាន់ស្មានតម្លៃគឺផ្អែកលើក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រងដែលត្រូវជ្រើសតាំងដោយភាគីទាំងពីរ ។

ការប៉ាន់តម្លៃទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ដោយរោងចក្រផលិត ភ្នាក់ងារផ្តាច់មុខ ឬភ្នាក់ងារដែលទទួលបានការអនុញ្ញាត ជើងសារដែលទទួលបានការអនុញ្ញាត ឬក្រុមហ៊ុនចែកចាយដែលទទួលបានការអនុញ្ញាត ឬក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង គឺជាភស្តុតាងដែលប្រាកដប្រជាពាក់ព័ន្ធនឹងតម្លៃទីផ្សារនៃទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង នៅក្នុងនីតិវិធីច្បាប់ណាមួយប្រឆាំងនឹងក្រុមហ៊ុន ។

ទំព័រនេះត្រូវបានទុកចោលដោយចេតនា